# <u>សេចក្តីថ្លែងការណ៍រួម</u>

**ភ្នំពេញ ថ្ងៃព្រហស្បតិ៍ ទី៣ ខែឧសភា ឆ្នាំ២០២៤ ៖** អង្គការសង្គមស៊ីវិល សមាគម និងស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ និងដៃគូអភិវឌ្ឍន៍ផ្សេងៗ បានរួមគ្នារៀបចំព្រឹត្តិការណ៍ដើម្បីរំលឹកខួបលើកទី៣១ នៃទិវាសេរីភាពសារព័ត៌មានពិភពលោក។ ដោយមានអ្នកចូលរួមប្រហែល ២២២នាក់ រួមមានអ្នកសារព័ត៌មាន អ្នកតំណាងអង្គការសង្គមស៊ីវិល យុវជន និងភាគីពាក់ព័ន្ធផ្សេងៗទៀត បានចូលរួមព្រឹត្តិការណ៍នេះដោយផ្ទាល់ និងតាមរយៈការផ្សាយផ្ទាល់នៅលើអនឡាញ ដើម្បីចូលរួមអបអរសាទរតួនាទីដ៏សំខាន់នៃសារព័ត៌មាន ក្នុងការចូលរួមដោះស្រាយវិបត្តិបរិស្ថាន។

ឆ្នាំនេះ ប្រធានបទ នៃទិវាសេរីភាពសារព័ត៌មានពិភពលោកគឺផ្តោតសំខាន់លើ «សារព័ត៌មានសម្រាប់ភពផែនដី៖ សារព័ត៌មានក្នុងបរិបទនៃវិបត្តិបរិស្ថាន» ដែលសង្កត់ធ្ងន់លើតួនាទីដ៏សំខាន់នៃសារព័ត៌មានសេរីនិងឯករាជ្យ ក្នុងការដោះស្រាយបញ្ហាប្រឈមនៃបរិស្ថាន។ ជាការពិតណាស់ អ្នកសារព័ត៌មានដើរតួនាទីដ៏សំខាន់ ក្នុងការលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ដើម្បីធ្វើឱ្យអាជ្ញាធរមានគណនេយ្យភាព និងជំរុញឱ្យមានដំណោះស្រាយ។

នៅកម្ពុជា អ្នកសារព័ត៌មានដែលរាយការណ៍អំពីបញ្ហាបរិស្ថានតែងតែប្រឈមនឹងការគំរាមកំហែង ការយាយី និងអំពើហិង្សា។ យោងតាមរបាយការណ៍ចុងក្រោយរបស់សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) ស្តីពី «ស្ថានភាពសារព័ត៌មានកម្ពុជា» គឺមានករណីយាយីចំពោះអ្នកសារព័ត៌មានចំនួន ៣២ ករណីដែលបានកត់ត្រានៅក្នុងឆ្នាំ២០២៣ រួមទាំងករណីគំរាមកំហែងផ្លូវច្បាប់ចំនួន ១៥ ករណី។ ក្នុងនោះមានករណីចំនួន ៧ ក្នុងចំណោម ៣២ ករណីដែលជាប់ទាក់ទងទៅនឹងការរាយការណ៍អំពីបញ្ហាបរិស្ថាន។ ចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ២០២៤ ខេមបូចា ក៏បានកត់ត្រាករណីយារយីអ្នកសារព័ត៌មានចំនួន១០ករណី ក្នុងនោះមាន ៧ករណីនៃការគំរាមកំហែងផ្លូវច្បាប់។

ស្រដៀងគ្នានេះដែរ យោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២៣របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) សមាគមអាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព ស្តីពី «ការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា» មានអ្នកសារព័ត៌មានចំនួន២៦នាក់ បានប្រឈមមុខនឹងការរឹតបន្តឹង ឬការដាក់ទណ្ឌកម្មចំពោះការចុះបំពេញការងាររបស់ខ្លួននៅឆ្នាំ២០២៣។ អ្នកសារព័ត៌មានត្រូវបាននាំយកមកសួរនាំ បន្ទាប់ពីពួកគេបានធ្វើការស៊ើបអង្កេត ឬរាយការណ៍អំពីបញ្ហាសង្គម ដូចជា សកម្មភាពអាជីវកម្មខុសច្បាប់ អំពើពុករលួយ និងជម្លោះដីធ្លីជាដើម។

នៅក្នុងហេតុការណ៍ចំនួន ៥ ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ ឬអ្នកសារព័ត៌មានបានប្រឈមមុខនឹងការគំរាមកំហែងផ្លូវច្បាប់ ហើយត្រូវបានបង្គាប់ឱ្យកែសម្រួល ឬហាមមិនឱ្យចុះផ្សាយអត្ថបទរបស់ខ្លួន។ ជាងនេះទៅទៀត ក៏មានករណីរបស់អ្នកសារព័ត៌មានចំនួន៦ រូប ដែលធ្វើការនៅក្នុងស្ថាប័នប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ទទួលបានការវាយប្រហារ ឬរងរបួស និងមានករណីចំនួន៤ផ្សេងទៀត ដែលអ្នកសារព័ត៌មានត្រូវបានគេរឹបអូសនូវសម្ភារៈរបស់ពួកគេ នៅអំឡុងពេលពួកគេបំពេញការងារ។ កង្វះគណនេយ្យភាពចំពោះកំណត់ត្រាហេតុការណ៍ទាំងអស់នេះគឺជាបញ្ហាយ៉ាងធ្ងន់ធ្ងរនិងបង្កឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីការជ្រៀតជ្រែកនៅក្នុងសកម្មភាពការងាររបស់អ្នកសារព័ត៌មាន។

ដោយសារតែអ្នកសារព័ត៌មានដើរតួនាទីយ៉ាងសំខាន់ក្នុងការតស៊ូមតិសម្រាប់ដោះស្រាយបញ្ហាបរិស្ថាន និងផ្តល់នូវការអនុវត្តល្អជាច្រើន ក្នុងនាមយើងខ្ញុំជាអង្គការសង្គមស៊ីវិល និងស្ថាប័ន ប្រព័ន្ធ ផ្សព្វផ្សាយដែលបានខិតខំស្វះស្វែងលើកកម្ពស់សិទ្ធិទទួលព័ត៌មាន សេរីភាពសារព័ត៌មាន និងសេរីភាពបញ្ចេញមតិនៅកម្ពុជា សូមអំពាវនាវឱ្យមានការគាំទ្របន្ថែមទៀតពីដៃគូអភិវឌ្ឍន៍ ដើម្បីឱ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអង្គការសង្គមស៊ីវិល ផ្តល់នូវការគាំពារ និងជំនួយបន្ទាន់ដល់អ្នកសារព័ត៌មាន ដែលងាយរងហានិភ័យ។

យើងខ្ញុំសូមអំពាវនាវបន្ថែមទៀតទៅដល់រាជរដ្ឋាភិបាលកម្ពុជា ផ្តល់អាទិភាពនូវសំណើដូចខាងក្រោមនេះ ៖

១. សូមធានាឱ្យបរិយាកាសសង្គម ទាំងនៅលើបណ្តាញអនឡាញ និងក្រៅបណ្តាញ មាន សេរីភាព និងសុវត្ថិភាពសម្រាប់អ្នកសារព័ត៌មាន និងស្ថាប័នព័ត៌មានដើម្បីបំពេញតួនាទីវិជ្ជាជីវៈ ដោយគ្មានឧបសគ្គ ឬការព្រួយបារម្ភ ជាពិសេសនៅពេលពួកគេរាយការណ៍អំពីបញ្ហាបរិស្ថាន។

២. សូមបញ្ឈប់រាល់ទម្រង់នៃការយាយីដល់ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានដែលរាយការណ៍អំពីបញ្ហាសង្គមដ៏រសើប។

៣. សូមបញ្ឈប់ការប្រើប្រាស់បទប្បញ្ញត្តិព្រហ្មទណ្ឌដើម្បីដាក់ទោសអ្នកសារព័ត៌មាន ចំពោះការបំពេញតួនាទីស្របច្បាប់របស់ពួកគេដោយអយុត្តិធម៌។

៤. សូមពន្លឿននូវការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែលស្របតាមស្តង់ដារអន្តរជាតិ និងធានានូវការអនុវត្តយ៉ាងម៉ត់ចត់។

៥. សូមចូលរួមក្នុងការពិគ្រោះយោបល់បើកចំហជាមួយភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីពិភាក្សាអំពីវិសោធនកម្មច្បាប់ស្តីពីសារព័ត៌មាន។

៦. សូមប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាលើយេនឌ័រដែលផ្តោតសំខាន់លើអ្នកសារព័ត៌មានជាស្ត្រី និងចាត់វិធានការចាំបាច់ដើម្បីបង្កើនតំណាងស្ត្រីនៅក្នុងវិស័យសារព័ត៌មាន៕

**សេចក្តីថ្លែងការណ៍រួមនេះ គាំទ្រដោយ ៖**

១. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)
២. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
៣. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
៤. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
៥. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
៦. បណ្តាញយុវជនកម្ពុជា (CYN)
៧. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
៨. អង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC)
៩. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
១០. អង្គការតម្លាភាពកម្ពុជា (TIC)
១១. បណ្តាញអ្នកសារព័ត៌មានស្ត្រីកម្ពុជា (CFJ)

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖**

**លោក ណុប វី** នាយកប្រតិបត្តិ នៃសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)

012 519 261; ed@camboja.net

**លោក អ៊ុិត សូធឿត** ប្រធានផ្នែកប្រព័ន្ធផ្សព្វផ្សាយ នៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)

012819545, isothoeuth@ccimcambodia.org

**លោក ហួន ផន** អ្នកសម្របសម្រួលគម្រោង នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

070 757 884, phorn@cchrcambodia.org